សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation
CAMBODIA RICE FEDERATION

លេខ:០០២៤/១៥ ស.អ.ក

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មាធិការទទួលបន្ទុកធ្វើការផ្សព្វផ្សាយទីផ្សារសំរាប់នាំចេញអង្ករកម្ពុជា
(Global Market Promotion Executive Committee)

## ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា

- បានឃើញអនុក្រឹត្យស្តីពីការទទួលស្គាល់នៃការបង្កើតសហព័ន្ធស្រូវអង្ករកម្ពុជា លេខ២២៨ អនក្រ.បក ចុះថ្ងៃទី ៨ សីហា ឆ្នាំ ២០១៤ ដោយនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលក្ខន្តិកៈសហព័ន្ធស្រូវអង្ករកម្ពុជា អនុម័តដោយអង្គមហាសន្និបាតកាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥
- យោងតាមការចាំបាច់របស់សហព័ន្ធស្រូវអង្ករកម្ពុជា

## សម្រេច

**ប្រការ១.**

បង្កើតគណៈកម្មាធិការ ទទួលបន្ទុករកទីផ្សារសំរាប់នាំចេញ (Global Market Promotion Executive Committee) ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១.កញ្ញា ថេ សុខា នាយកប្រចាំប្រទេស ក្រុមហ៊ុន ETG | ប្រធាន |
| ២. លោកស្រី គឹម ស្រីរ័ត្ន នាយកក្រុមហ៊ុនខ្មែរហ្វូត | អនុប្រធាន |
| ៣. លោក ម៉ៅ គង់ នាយកចាត់ការទូទៅក្រុមហ៊ុន Loran | សមាជិក |
| ៤. លោក អ៊ុត វិជិត ទីប្រឹក្សាជាន់ខ្ពស់របស់សហព័ន្ធស្រូវអង្ករកម្ពុជា | សមាជិក |
| ៥. លោក វ៉ាន់ វិចិត្រ ទីប្រឹក្សាជាន់ខ្ពស់របស់សហព័ន្ធស្រូវអង្ករកម្ពុជា | សមាជិក |
| ៦. លោក យ៉ាន់ ពេជ្រ មន្ត្រីសហព័ន្ធស្រូវអង្ករកម្ពុជា | សមាជិក |
| ៧. លោក ចាន់ ពេជ្រ ប្រធានទីផ្សារក្រុមហ៊ុន Signature of Asia | សមាជិក |
| ៨.លោក អ៊ឹង ឈាងសៀ ប្រធានក្រុមហ៊ុន សេកមាស | សមាជិក |
| ៩. លោក Remi Collete ប្រធានទីផ្សារ ក្រុមហ៊ុន Hung Hiep | សមាជិក |
| ១០. លោក លឹម យ៉ារ៉េត ប្រធានក្រុមហ៊ុន White Gold | សមាជិក |
| ១១. លោក ជិន ឆារ៉ុម ប្រធានក្រុមហ៊ុន HLCP | សមាជិក |
| ១២. លោក ពៅ បុណ្ណរិទ្ធ មន្ត្រីសហព័ន្ធស្រូវអង្ករកម្ពុជា | លេខាធិការ |

#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia • Tel: +855 23 722 250 • Mail: info@crf.org.kh

**ប្រការ២.**

គណៈកម្មាធិការមានភារៈកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្តលើកិច្ចការនៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងផែនការសកម្មភាពដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល តាមការងារដូចខាងក្រោម៖

- ជួសមុខអោយសហព័ន្ធ ក្រុមប្រឹក្សាភិបាល សហព័ន្ធ ធ្វើការរៀបចំយុទ្ធសាស្ត្រ និងអនុវត្តលើការងារការបង្កើតម៉ាកយីហោអង្ករកម្ពុជា (CAMBODIAN RICE BRAND)សំរាប់ធ្វើការផ្សព្វផ្សាយ និងជំរុញការលក់អង្ករកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ
- កំណត់នូវយុទ្ធសាស្ត្រទីផ្សារ ការពង្រីក និងពង្រឹងភាពប្រកួតប្រជែងអង្ករកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។
- ជួសមុខអោយសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ក្នុងការចរចារជាមួយក្រសួង ស្ថាប័នជាតិ អន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍន៍នានា ក្នុងការស្វែងរកនូវកិច្ចសហប្រតិបត្តិការ ការកៀងគររកនូវជំនួយសំរាប់ជួយដល់ការធ្វើសកម្មភាពការជំរុញការផ្សព្វផ្សាយ អង្ករកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។
- គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ ជាទៀតទាត់ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។ ចំពោះករណីការងារណាដែលមិនមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលអនុញ្ញាត្តិសំរេចជាមុន។
- ក្នុងករណីចំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និង ទីប្រឹក្សាសំរាប់គណៈកម្មាធិការនេះ។

**ប្រការ៣.**

ក្រុមប្រឹក្សាភិបាល លេខាធិការដ្ឋាន ការិយាល័យសាខាតាមខេត្ត និងសាមីខ្លួនត្រូវអនុវត្តន៍ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានី ភ្នំពេញ ថ្ងៃទី១៩ ខែ មិនា ឆ្នាំ២០១៥

**ប្រធាន**

CAMBODIA RICE FEDERATION

**សុខ ពុទ្ធិវុធ**

ចំលងជូន

- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- គំពាងពាណិជ្ជកម្មស្រូវនៅកម្ពុជា របស់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ
- ដៃគូអភិវឌ្ឍន៍ IFC, AFD
- ដូចប្រការ ៣
- ឯកសារ កាលប្បវត្តិ